**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ** ០៣០/០៥ **គ.ជ.ប**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី ៤ ឆ្នាំ ២០០៨

អនុលោមតាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ បទបញ្ជា និង នីតិវិធី សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជូនដំណឹងដល់គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីត្រឹមត្រូវនៅក្រសួងមហាផ្ទៃ ហើយដែលមានបំណងសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី **២៧** ខែ **កក្កដា** ឆ្នាំ **២០០៨** ឱ្យបានជ្រាបថា ៖

- កាលបរិច្ឆេទទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ចាប់ផ្តើមពីថ្ងៃទី **២៨** ខែ **មេសា** ឆ្នាំ **២០០៨** បញ្ចប់នៅថ្ងៃទី **១២** ខែ **ឧសភា** ឆ្នាំ **២០០៨** ។
- គណបក្សនយោបាយ ដែលមានបំណងឈរឈ្មោះបោះឆ្នោត ត្រូវមកយកគំរូពាក្យសុំ និង ដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៅការិយាល័យទំនាក់ទំនងគណបក្សនយោបាយ និងទទួលស្គាល់អ្នកសង្កេតការណ៍ ( **បន្ទប់ A 24** ) នៃនាយកដ្ឋានសេវាកម្មច្បាប់ និង វិវាទកម្មនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត រៀងរាល់ម៉ោងធ្វើការ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្ឃឹមទុកជាមុនថា គ្រប់គណបក្សនយោបាយដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រអាណត្តិទី ៤ នឹងអនុវត្តតាមសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ ២០០៨

**ត.ប. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**អគ្គលេខាធិការ**

**ទេព_នីថា**